**Cambodian - Impetigo (school sores)**

ជម្ងឺឆ្លង - វ៉ាយរិស



# ជម្ងឺពងខ្ទុះលើស្បែក - ដំបៅសាលា

## ចំណុចសំខាន់។

- ជម្ងឺពងខ្ទុះលើស្បែក គឺជាមេរោគបាក់តេរីផ្នែកខាងលើស្បែក
- ជម្ងឺពងខ្ទុះលើស្បែក ច្រើនកើតមាននៅពីលើមុខ ដៃ ឬជើង
- ជម្ងឺពងខ្ទុះលើស្បែកគឺជាជម្ងឺឆ្លង ហើយអាចឆ្លងរាលដាលពីសមាជិកគ្រួសារម្នាក់ ទៅម្នាក់ទៀត ហើយពីក្មេងសាលាម្នាក់ ទៅម្នាក់ទៀត
- ជម្ងឺពងខ្ទុះលើស្បែក អាចព្យាបាលជាមួយថ្នាំទឹកសម្លាប់មេរោគស្បែក។ គេអាចប្រើថ្នាំផឹកអង់ទីប៊ីយ៉ូទិក ឬក្រែមអង់ទីប៊ីយ៉ូទិក ប្រើពីលើស្បែក ដើម្បីព្យាបាលផងដែរ។

## តើវាជាអ្វី?

ជម្ងឺពងខ្ទុះលើស្បែក គឺជាមេរោគឆ្លងនៅលើស្បែក ដែលបណ្ដាលឲ្យក្រៀម ចេញទឹក ហើយជួនកាលពងខ្ទុះនៅលើស្បែក។ វាលេចចេញក្នុងរយៈពេលពីរ ឬបីថ្ងៃពីលើស្បែកដូចជានៅលើមុខ ឬដៃជើង។ ពេលខ្លះវាអាចឆ្លងរាលដាលដល់ដងខ្លួន។

វាជាជម្ងឺមួយដែលឆ្លងខ្លាំងណាស់ ហើយអាចឆ្លងរាលដាលពីសមាជិកគ្រួសារម្នាក់ ទៅម្នាក់ទៀត ឬអាចឆ្លងរាលដាលពីក្មេងសាលាម្នាក់ ទៅម្នាក់ទៀត។ ហេតុដូច្នេះហើយបានជាគេដាក់ឈ្មោះវាថា "school sores" (ដំបៅសាលា)។

ធម្មតាជម្ងឺនេះមិនបណ្ដាលឲ្យកើតមានរោគសញ្ញាអ្វីឡើយ ហើយមិនទាំឲ្យកើតមានស្លាកស្នាមអ្វីទេ។ ជួនកាលវាអាចកើតមានជម្ងឺស្បែក ដូចជាជម្ងឺរលាកស្បែក។ ការនេះអាចបណ្ដាលឲ្យជម្ងឺរលាកស្បែកកើតមានកាន់តែធ្ងន់ធ្ងរឡើង ដែលមានចេញទឹក និងក្រៀមលឿង។

## តើគេព្យាបាលវាដោយរបៀបណា?

ជម្ងឺពងខ្ទុះលើស្បែកអាចចាប់ផ្ដើមបន្ទាប់ពីការអេះរមាស់ដែលបណ្ដាលមកពីសត្វល្អិតខាំ ឬពីការដាច់ស្បែកបន្តិចបន្តួច។ ដើម្បីការពារកុំឲ្យកើតមានជម្ងឺនេះ គេត្រូវប្រើថ្នាំសម្លាប់មេរោគនៅត្រង់កន្លែងមុត ឬដាំច់ស្បែក។

ការលាងសំអាតស្បែកដែលមានមេរោគជាមួយថ្នាំទឹកសម្លាម់មេរោគ ហើយប្រើក្រែមសម្លាប់មេរោគដែលវេជ្ជបណ្ឌិតចេញបញ្ជាឲ្យប្រើ អាចជួយព្យាបាលជម្ងឺពងខ្ទុះលើស្បែកដែលមិនធ្ងន់ធ្ងរ។ ប្រសិនបើជម្ងឺនេះវាឆ្លងរាលដាលខ្លាំង វេជ្ជបណ្ឌិតអាចចេញថ្នាំផឹកអង់ទីប៊ីយ៉ូទិក ដើម្បីប្រើជាមួយថ្នាំសម្លាប់មេរោគ។

កុមារដែលកើតជម្ងឺពងខ្ទុះលើស្បែក ត្រូវតែដាក់ឲ្យបាននៅឆ្ងាយពីក្មេងឯទៀត។ ក្នុងរយៈពេល២៤ម៉ោងបន្ទាប់ពីបានចាប់ផ្ដើមព្យាបាលជាមួយថ្នាំផឹកអង់ទីប៊ីយ៉ូទិកមក កុមារនឹងឈប់ចម្លងមេរោគ ហើយឈប់ឆ្លងរាលដាលទៅដល់អ្នកឯទៀត។

## ពត៌មានបន្ថែមទៀត

- គិលានុបដ្ឋាយិកាមើលថែទាំសុខភាពមាតា និងកុមារ
- ឱសថការីរបស់លោកអ្នក
- វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក
- វេជ្ជបណ្ឌិតឯកទេសជម្ងឺសើរស្បែក

© 2002, Department of Dermatology, St. Vincent's Hospital Melbourne, Victoria Parade, Fitzroy, Victoria 3065 Australia.